លេខ 2617
ថ្ងៃទី 02.06.22

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ :** ៤១៦ សជណ.

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង**

**កម្មវត្ថុ** ៖ ករណីលទ្ធផលនៃការចុះពិនិត្យស្ថានភាពនៃការកាន់កាប់ដីរបស់ប្រជាពលរដ្ឋ ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពង់ឆ្នាំង ដែលជាប់ពាក់ព័ន្ធនឹងតំបន់២ និងតំបន់៣ នៃទន្លេសាប និងសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣។

**យោង** ៖
- លិខិតលេខ១៣៨៥ ដនស/អសដក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ២៧១ ខន/០២២ សជណ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

- កាត់ឆ្វៀលដីសម្រាប់លំនៅឋាន ទំហំ ១៨ហិកតា ៧៨អា ២៩សង់ទីអា ចេញពីតំបន់៣ នៃទន្លេសាប កំណត់ដោយអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់មកជាមួយ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៥១៦គ្រួសារ ដែលរស់នៅជាក់ស្តែងជាអចិន្ត្រៃយ៍ ស្ថិតនៅភូមិសំពោងសែន និងភូមិប៉ប្រក ឃុំសំពោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដោយសំអាងថា ទីតាំងនេះជាស្ថានីយបុរេប្រវត្តិសំពោងសែន ៣០៣២ឆ្នាំ ដល់ ១២៨០ឆ្នាំ មុន គ.ស.

- កែសម្រួលផ្ទៃដីទំហំ ១ ០៣៧ហិកតា ស្ថិតនៅភូមិសំពោងសែន និងភូមិប៉ប្រក ឃុំសំពោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ចេញពីតំបន់៣ បញ្ចូលមកតំបន់២ នៃទន្លេសាប ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់មកជាមួយ និងប្រគល់ជូនប្រជាពលរដ្ឋចំនួន ៥១៦គ្រួសារ ប្រើប្រាស់ និងអាស្រ័យផល ដោយមួយគ្រួសារទទួលបានដីទំហំ ២ហិកតា និងផ្ទៃដីទំហំ ៥ហិកតា ត្រៀមបម្រុងទុកសម្រាប់បម្រើប្រយោជន៍សាធារណៈ

- កាត់ឆ្វៀលដីទំហំ ២៣៤ហិកតា ៤០អា ស្ថិតនៅភូមិថ្នល់ឈើទាល ភូមិពាមខ្នង និងភូមិស្លូត ចេញពីតំបន់៣នៃទន្លេសាប កំណត់ដោយអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់មកជាមួយ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ១៧២គ្រួសារ ដែលរស់នៅជាក់ស្តែងជាអចិន្ត្រៃយ៍ ដោយក្នុងមួយគ្រួសារទទួលបានដីលំនៅឋានទំហំ ២០ម x១០០ម

- កែសម្រួលផ្ទៃដីទំហំ ២ ៣៥៤ហិកតា ស្ថិតនៅភូមិថ្នល់ឈើទាល ភូមិពាមខ្នង និងភូមិស្លូត នៅបន្តពីប្រឡាយក្រោយដីលំនៅឋានរបស់ប្រជាពលរដ្ឋ ចេញពីតំបន់៣ បញ្ចូលមកតំបន់២នៃទន្លេសាប ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់មកជាមួយ និងប្រគល់ជូនប្រជាពលរដ្ឋចំនួន ១ ១៧២គ្រួសារ ប្រើប្រាស់ និងអាស្រ័យផល ដោយមួយគ្រួសារទទួលបានដីទំហំ ២ហិកតា និងផ្ទៃដីទំហំ ១០ហិកតា ត្រៀមបម្រុងទុកសម្រាប់បម្រើប្រយោជន៍សាធារណៈ

- ក្នុងភូមិសាស្ត្រឃុំកំពង់ហៅ ឃុំត្រងិល ឃុំស្វាយរំពារ ឃុំដារ ឃុំច្រណូក និងឃុំពោធិ៍ នៃស្រុកកំពង់លែង រដ្ឋបាលខេត្តកំពង់ឆ្នាំងត្រូវចុះកំណត់ទីតាំងនិងអត្តសញ្ញាណ រួចលើកសំណើសុំគោលការណ៍ពីរាជរដ្ឋាភិបាលនូវទីតាំងដីដែលប្រជាពលរដ្ឋបានកាន់កាប់ និងរស់នៅតាមបណ្តោយសង្វាងផ្លូវ ៥០C ដែលមិនពាក់ព័ន្ធនឹងតំបន់២ ឬតំបន់៣នៃទន្លេសាប តែមានការពាក់ព័ន្ធនឹងស្មារតីនៃសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ដែលបានហាមឃាត់មិនឱ្យមានការចុះបញ្ជីនៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវទឹកឡើងជុំវិញទន្លេសាប

- ក្នុងភូមិសាស្ត្រស្រុកកំពង់ត្រឡាច ស្រុករលាប្អៀរ ក្រុងកំពង់ឆ្នាំង និងស្រុកបរិបូណ៌ រដ្ឋបាលខេត្តកំពង់ឆ្នាំងត្រូវចុះកំណត់ទីតាំង និងអត្តសញ្ញាណនូវដីលំនៅឋានរបស់ប្រជាពលរដ្ឋតាមបណ្តោយផ្លូវជាតិលេខ៥ រួចលើកសំណើសុំគោលការណ៍ពីរាជរដ្ឋាភិបាលកែសម្រួលពីតំបន់២ទៅតំបន់១ និងចុះបញ្ជីផ្តល់បណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូន:**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរទន្លេសាប
- រដ្ឋបាលជលផល
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១២២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ឆ្វៀលផ្ទៃដីតំបន់៣ និងការកែសម្រួលផ្ទៃដីតំបន់៣ ស្ថិតក្នុងភូមិសាស្ត្រឃុំសំរោងសែន និងឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- សារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋដែលកាន់កាប់ និងប្រើប្រាស់ជាក់ស្តែងនៅតំបន់ទំនាបដែនលិចទឹកក្នុងរដូវជំនោរឡើងនៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១.-**

កាត់ឆ្វៀលផ្ទៃដីទំហំ ២៥៣ ហិកតា ១៨អា ២៩សង់ទីអា ស្ថិតក្នុងភូមិសាស្ត្រស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ចេញពីតំបន់៣ នៃទន្លេសាប ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ៦៨៨គ្រួសារ ដែលបានរស់នៅជាក់ស្តែងជាអចិន្ត្រៃយ៍ ក្នុងនោះ ៖

១. ឃុំសំរោងសែន ដីទំហំ ១៨ហិកតា ៧៨អា ២៩សង់ទីអា ស្ថិតនៅភូមិសំរោងសែន និងភូមិប៉ប្រេក ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៥១៦គ្រួសារ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

២. ឃុំផ្លូវទូក ដីទំហំ ២៣៤ហិកតា ៤០អា ស្ថិតនៅភូមិថ្នល់ឈើទាល ភូមិពាមខ្ទង និងភូមិស្លត ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១ ១៧២គ្រួសារ ដោយមួយគ្រួសារទទួលបានដីលំនៅឋាន ទំហំ ២០ម x ១០០ម ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

កែសម្រួលផ្ទៃដីទំហំ ៣ ៣៩១ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ចេញពីតំបន់៣ នៃទន្លេសាប ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ បញ្ចូលមកតំបន់២ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងប្រគល់ជូនប្រជាពលរដ្ឋចំនួន ១ ៦៨៨គ្រួសារ ប្រើប្រាស់ និងអាស្រ័យផលក្នុងនោះ ៖

១. ឃុំសំរោងសែន ដីទំហំ ១ ០៣៧ហិកតា ស្ថិតនៅភូមិសំរោងសែន និងភូមិប៉ប្រេក ជូនប្រជាពលរដ្ឋចំនួន ៥១៦គ្រួសារ ដោយមួយគ្រួសារទទួលបានដីទំហំ ២ហិកតា និងផ្ទៃដីទំហំ ៥ហិកតា ត្រៀមបម្រុងទុកសម្រាប់បម្រើប្រយោជន៍សាធារណៈ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

២. ឃុំផ្លូវទូក ដីទំហំ ២ ៣៥៤ ហិកតា ស្ថិតនៅភូមិថ្នល់ឈើទាល ភូមិពាមខ្ទង និងភូមិស្លត ជូនប្រជាពលរដ្ឋចំនួន ១ ១៧២គ្រួសារ ដោយមួយគ្រួសារទទួលបានដីទំហំ ២ហិកតា និងផ្ទៃដីទំហំ ១០ហិកតា ត្រៀមបម្រុងទុកសម្រាប់បម្រើប្រយោជន៍សាធារណៈ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរទន្លេសាប និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ